ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៦។

ADB ASIAN DEVELOPMENT BANK

# ប្រទេសកម្ពុជា ៖ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជីវភាពកសិករខ្នាតតូចតំបន់ទន្លេសាប - ការផ្តល់ហិរញ្ញប្បទានបន្ថែម

| | |
|---|---|
| **ឈ្មោះគម្រោង** | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជីវភាពកសិករខ្នាតតូចតំបន់ទន្លេសាប - ការផ្តល់ហិរញ្ញប្បទានបន្ថែម |
| **លេខគម្រោង** | 41435-054 |
| **ប្រទេស** | កម្ពុជា |
| **ស្ថានភាពគម្រោង** | ស្នើ |
| **ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ** | ជំនួយឥតសំណង<br>កម្ចី |
| **ប្រភពមូលនិធិ/ចំនួនទឹកប្រាក់** | **ជំនួយឥតសំណង៖ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជីវភាពកសិករខ្នាតតូចតំបន់ទន្លេសាប**<br>មូលនិធិអភិវឌ្ឍន៍អាស៊ី — ៤,៥៣ លានដុល្លារ<br>**កម្ចី៖ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជីវភាពកសិករខ្នាតតូចតំបន់ទន្លេសាប**<br>មូលនិធិអភិវឌ្ឍន៍អាស៊ី — ៤៥,៤៧ លានដុល្លារ |
| **របៀបវារៈយុទ្ធសាស្ត្រ** | កំណើនដែលធានានិរន្តរភាពបរិស្ថាន<br>កំណើនសេដ្ឋកិច្ចបរិយាប័ន្ន |
| **កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ** | អភិបាលកិច្ច និងការអភិវឌ្ឍសមត្ថភាព |

| | |
|---|---|
| **វិស័យ/អនុវិស័យ** | កសិកម្ម ធនធានធម្មជាតិ និងការអភិវឌ្ឍជនបទ - ផលិតកម្មកសិកម្ម - ធារាសាស្ត្រ |
| **សមធម៌យេនឌ័រ និងការបញ្ជ្រាបយេនឌ័រ** | ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព |
| **ការពណ៌នា** | ការផ្តល់ហិរញ្ញប្បទានបន្ថែមដល់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជីវភាពកសិករខ្នាតតូចតំបន់ទន្លេសាប ត្រូវបានស្នើឡើង សម្រាប់ខេត្តចំនួន ៧ (បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ធំ ព្រៃវែង សៀមរាប និងត្បូងឃ្មុំ) ក្នុងប្រទេសកម្ពុជា។ ការផ្តល់ហិរញ្ញប្បទានបន្ថែមនេះ នឹងបង្កើនផលិតភាពកសិកម្ម ក៏ដូចជាលើកកម្ពស់លទ្ធភាពទទួលបានទីផ្សារ ក្នុងឃុំគោលដៅចំនួន ២៧០ តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផលិតកម្មដែលធន់ទៅនឹងអាកាសធាតុ ការកសាងសមត្ថភាពគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយរបស់សហគមន៍ និងក្រុមប្រឹក្សាឃុំ និងការបង្កើតនូវបរិយាកាសអំណោយផលសម្រាប់បង្កើនផលិតភាព ពិពិធកម្ម និងភាពធន់ទ្រាំទៅនឹងអាកាសធាតុនៃសកម្មភាពកសិកម្ម។ |
| **វិចារណភាពគម្រោង និងការតភ្ជាប់ ទៅនឹងយុទ្ធសាស្ត្រប្រទេស/តំបន់** | ដោយសារជោគជ័យនៃគម្រោងបច្ចុប្បន្ននេះ ទីភ្នាក់ងារប្រតិបត្តិបានស្នើសុំឲ្យធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ការគាំទ្រក្នុងទម្រង់ជាការផ្តល់ហិរញ្ញប្បទានបន្ថែម ដើម្បីពង្រីកសកម្មភាពគម្រោងបច្ចុប្បន្ននេះ។ តម្រូវការហេដ្ឋារចនាសម្ព័ន្ធផលិតកម្មកសិកម្ម សម្រាប់កាត់បន្ថយភាពក្រីក្រ ក្នុងតំបន់បឹងទន្លេសាប គឺមានកម្រិតខ្ពស់។ ជាង ៩០% នៃប្រជាជនក្រីក្រ រស់នៅតំបន់ជនបទ ពឹងអាស្រ័យលើផលិតកម្មកសិកម្មខ្នាតតូច សម្រាប់ចិញ្ចឹមជីវិត។ ភាពកើតឡើងញឹកញាប់ និងភាពខ្លាំងក្លានៃគ្រោះមហន្តរាយនានា ដូចជា គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក្នុងតំបន់អាងទន្លេសាប ទាមទារឲ្យមានការធ្វើអន្តរាគមន៍ ដើម្បីលើកកម្ពស់ភាពធន់ទ្រាំទៅនឹងអាកាសធាតុ និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ ការផ្តល់ហិរញ្ញប្បទានបន្ថែមនេះក៏នឹងពង្រឹងវិធីសាស្ត្រជាយុទ្ធសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់តំបន់អាងទន្លេសាបទាំងមូល តាមរយៈការផ្គួបកម្លាំងជាមួយនឹងគម្រោងផ្សេងទៀត ដូចជា កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជភាវូបនីយកម្មស្រូវអង្ករដែលធន់នឹងអាកាសធាតុ (ហៅកាត់ថា Rice SDP) ជាដើម។ លើសពីនេះ តាមរយៈការប្រើប្រាស់គំរូផ្តល់ហិរញ្ញប្បទានបន្ថែម គេអាចបន្តប្រើប្រាស់ភាពជោគជ័យដែលសម្រេចបានកន្លងមក និងប្រើប្រាស់ធនធានគម្រោងបច្ចុប្បន្នឲ្យបានល្អបំផុត។ |
| **ផលប៉ះពាល់** | មុខរបរចិញ្ចឹមជីវិតក្នុងឃុំគោលដៅ ក្នុងខេត្តចំនួន ៧ ដែលស្ថិតក្នុងតំបន់អាងទន្លេសាប ត្រូវបានលើកកម្ពស់។ |

| | |
|---|---|
| **លទ្ធផល** | ផលិតភាពកសិកម្មត្រូវបានបង្កើន ហើយលទ្ធភាពទទួលបានទីផ្សារត្រូវបានលើកកម្ពស់ ក្នុង ២៧០ ឃុំ ក្នុងខេត្តចំនួន ៧ ក្នុងតំបន់អាងទន្លេសាប។ |
| **ទិន្នផល** | ការអភិវឌ្ឍដឹកនាំដោយសហគមន៍ តាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធដែលបម្រើដល់ផលិតកម្មនៅជនបទ ដោយមានការពិចារណាលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបង្កើនសមត្ថភាពគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។<br><br>បរិយាកាសអំណោយផល សម្រាប់បង្កើនផលិតភាព ពិពិធកម្ម និងភាពធន់ទ្រាំទៅនឹងអាកាសធាតុ ត្រូវបានបង្កើតឡើង។<br><br>ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាពត្រូវបានធានា។ |
| **ទីតាំងភូមិសាស្ត្រ** | |

## ប្រភេទនៃកិច្ចការពារ

| | |
|---|---|
| បរិស្ថាន | B |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | B |
| ជនជាតិដើមភាគតិច | B |

## សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម

| | |
|---|---|
| **ទិដ្ឋភាពផ្នែកបរិស្ថាន** | |
| **ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត** | |
| **ជនជាតិដើមភាគតិច** | |

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

| | |
|---|---|
| ក្នុងអំឡុងពេលនៃការរៀបចំគម្រោង | |

ក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង

## បុគ្គលិកទទួលខុសត្រូវ

| | |
|---|---|
| មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | Dang, Thuy Trang |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | ផ្នែកបរិស្ថាន ធនធានធម្មជាតិ និងកសិកម្ម នៃនាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ទីភ្នាក់ងារប្រតិបត្តិ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>អគារលេខ ៤០ មហាវិថីព្រះនរោត្តម<br>រាជធានីភ្នំពេញ ប្រទេសកម្ពុជា<br>គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>ក្រសួងមហាផ្ទៃ  មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន<br>រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

## កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | ១៤ កញ្ញា ២០១៦ |
| បេសកកម្មស្វែងរកការពិត | ១៤ មេសា ២០១៧ ដល់ ២៨ មេសា ២០១៧ |
| កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង (MRM) | ២៩ មិថុនា ២០១៧ |
| ការអនុម័ត | - |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី មិនផ្តល់ការធានា ឬ ភាពជាតំណាងណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។